ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ភាពខុសគ្នា

## រវាង

# រដ្ឋសភា និង ព្រឹទ្ធសភា

រៀបរៀងដោយ៖ ថាត ចាន់ថា

Shared by page: Mr. That Chantha
https://www.facebook.com/thatchantha

# ភាពខុសគ្នារវាងរដ្ឋសភា និងព្រឹទ្ធសភា

ប្រទេសកម្ពុជាជាព្រះរាជាណាចក្រ ដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិ តាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត អចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ[1] មានទីតាំងស្ថិតនៅក្នុង ភូមិភាគអាស៊ី-អាគ្នេយ៍ មានផ្ទៃក្រឡា ១៨១.០៣៥ គីឡូម៉ែត្រការ៉េ មានភ្នំពេញជារាជធានី និងមាន រាជធានី-ខេត្តៈ ២៥ ក្រុង-ស្រុក-ខណ្ឌៈ ១៩៧ ឃុំ-សង្កាត់ៈ ១.៦៣៣ ភូមិៈ ១៤.១៣៩ មានប្រជាពលរដ្ឋ ១៥ លាននាក់[2] ។ ភាសា និងអក្សរដែល ប្រើជាផ្លូវការ គឺភាសា និងអក្សរខ្មែរ[3] ហើយព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ[4] ។ អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ហើយអំណាចបែងចែកដាច់ពីគ្នារវាង[5] អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។ ព្រឹទ្ធសភា និងរដ្ឋសភា ជាអង្គការមានអំណាចនីតិប្បញ្ញត្តិដូចគ្នា តែរដ្ឋសភា និងព្រឹទ្ធសភា មានអត្តសញ្ញាណ និងសមត្ថកិច្ចខុសគ្នា អាស្រ័យដោយៈ

### ក-ប្រភព

- តំណាងរាស្ត្រទាំងអស់ត្រូវជ្រើសតាំង តាមរយៈការបោះឆ្នោតសកល ដោយប្រជារាស្ត្រតាមមណ្ឌលខេត្ត-ក្រុងសម្រាប់រយៈពេល ៥ឆ្នាំ[6] ។
- សមាជិកព្រឹទ្ធសភាត្រូវជ្រើសតាំង តាមរយៈការបោះឆ្នោតអសកល ដោយក្រុមប្រឹក្សាឃុំ-សង្កាត់ និងតំណាងរាស្ត្រក្នុង តំណាងតាមភូមិ-ភាគ សម្រាប់រយៈពេល ៦ឆ្នាំ[7] ។ រួមជាមួយនោះមាន ២រូប ត្រូវបានតែងតាំងដោយ ព្រះមហាក្សត្រ និង ២រូបទៀត ត្រូវជ្រើសតាំង ដោយរដ្ឋសភា តាមមតិភាគច្រើនដោយប្រៀប[8]។

[1] មាត្រា ១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។
[2] http://www.worldbank.org/en/country/cambodia
[3] មាត្រា ៥ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។
[4] មាត្រា ៤៣ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។
[5] មាត្រា ៥១-ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។
[6] មាត្រា ៣-ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ១៩៩៧ និង ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ ២០០៧។
[7] មាត្រា ១០១-ថ្មី និង ១០២-ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។
[8] មាត្រា ១០០-ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

ដូច្នេះលក្ខណៈពិសេស របស់ព្រឹទ្ធសភា គឺព្រឹទ្ធសភាកើតឡើងដោយការបោះឆ្នោតជ្រើសតាំងផង និង ដោយការតែងតាំងផង ។

### ខ-ភាពជាតំណាង

- តំណាងរាស្ត្រជាតំណាង របស់ប្រជាពលរដ្ឋទូទៅជាម្ចាស់ឆ្នោតក្នុងមណ្ឌល។ បេក្ខជនតំណាង រាស្ត្រមានអាយុយ៉ាងតិច ២៥ ឆ្នាំ[9] ។
- សមាជិកព្រឹទ្ធសភាភាគច្រើន ជាតំណាងក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលម្ចាស់ឆ្នោត ប៉ុន្តែក៏មានតំណាងព្រះមហាក្សត្រ និងតំណាងរដ្ឋសភាផងដែរ។ បេក្ខជនសមាជិកព្រឹទ្ធសភាមានអាយុយ៉ាងតិច ៤០ ឆ្នាំ[10] ។

### គ-សមាជិកភាព

រដ្ឋសភាពមាន សមាជិកជាតំណាងរាស្ត្រយ៉ាងតិច ១២០រូប[11] (បច្ចុប្បន្ន ១២៣រូប) ហើយព្រឹទ្ធសភាមាន ចំនួនសមាជិកយ៉ាងច្រើន ស្មើនឹងចំនួនពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល[12]។

### ឃ-អំណាច

❖ ជ្រើសតាំងរាជរដ្ឋាភិបាល

រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល[13] និងអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីតំណែង[14]។ រដ្ឋសភាអាចត្រូវបានរំលាយមុនផុតអាណត្តិ បើសិនជារាជរដ្ឋាភិបាល ត្រូវបានទម្លាក់ពីរដងក្នុងរយៈពេល ១២ខែ[15]។ ព្រឹទ្ធសភាមិនអាចត្រូវរំលាយមុនចប់អាណត្តិបានទេ។

---

[9] មាត្រា ៧៦ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។
[10] មាត្រា ៩៩-ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។
[11] មាត្រា ៧៦ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។
[12] មាត្រា ៩៩-ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។
[13] មាត្រា ៩០-ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។
[14] មាត្រា ៩៨-ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។
[15] មាត្រា ៧៦ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

### ❖ សិទ្ធិវិសោធនកម្មរដ្ឋធម្មនុញ្ញ

មាត្រា១៥១ថ្មី នៃរដ្ឋធម្មនុញ្ញផ្តល់សិទ្ធិផ្តួចផ្តើមគំនិតសេរីរើ ឬផ្តួចផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញដល់ប្រធានរដ្ឋសភា តាមសេចក្តីស្នើរបស់តំណាងរាស្ត្រ មួយភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល ប៉ុន្តែរដ្ឋធម្មនុញ្ញពុំបានផ្តល់សិទ្ធិផ្តួចផ្តើមគំនិតនេះដល់ប្រធាន។

### ❖ សិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់

សមាជិករដ្ឋសភា ឬសមាជិកព្រឹទ្ធសភា មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ដូចគ្នា។ សេចក្តីស្នើច្បាប់ណាដែលផ្តួចផ្តើមធ្វើ ដោយសមាជិកព្រឹទ្ធសភា ត្រូវតែបញ្ជូនទៅរដ្ឋសភាអនុម័តជាលើកដំបូងរួច ហើយទើបបញ្ជូនមកព្រឹទ្ធសភាពិនិត្យ និងអោយយោបល់ស្រប តាមមាត្រា ១១៣ថ្មី។

### ❖ ការត្រួតពិនិត្យលើរាជរដ្ឋាភិបាល

រដ្ឋសភាមានអំណាច តាមច្បាប់ក្នុងការចោទសួរដេញដោល និងអនុម័តញ្ញត្តិបន្ទោសដកហូតតំណែង ឬរំលាយរាជរដ្ឋាភិបាល។ ផលិតច្បាប់អោយ បានល្អជាគោលដៅអាទិភាពរបស់ព្រឹទ្ធសភា ដោយមិនចំណុះបរិយាកាសនយោបាយ និងកាលៈទេសៈឡើយ។ ព្រឹទ្ធសភាមិនប្រឈមនឹង រាជរដ្ឋាភិបាលដូចរដ្ឋសភា ដោយប្រើញត្តិបន្ទោសដើម្បីដកហូតមុខតំណែងសមាជិករាជរដ្ឋាភិបាលឬរំលាយរាជរដ្ឋាភិបាលឡើយ។ ជាទូទៅព្រឹទ្ធសភាជាកូនជញ្ជីង ដើម្បីធ្វើអោយច្បាប់មានតុល្យភាព ដែលអាចទទួលយកបានពីរដ្ឋសភារាជរដ្ឋាភិបាល និងពីសំណាក់ប្រជាពលរដ្ឋដោយគ្មានស្ថាប័នណាមួយទៀត អាចប្រឡូកនៅក្នុងការដ្ឋាននេះឡើយ ក្រៅពីព្រឹទ្ធសភា លើកលែងក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានសិទ្ធិសម្រេចអំពីធម្មនុញ្ញភាពនៃច្បាប់ មុននឹងប្រកាសអោយប្រើ ហើយសម្រាប់តែច្បាប់ធម្មនុញ្ញ និងច្បាប់រៀបចំអង្គការតែប៉ុណ្ណោះ[16]។ ដូច្នេះច្បាប់ជាទូទៅផ្តើមចេញ ពីចរិតខុសគ្នានេះយោបល់ និងការឆ្លុះបញ្ចាំងរបស់ព្រឹទ្ធសភា អាចខុសគ្នាពីរដ្ឋសភា។ យោបល់និងការឆ្លុះបញ្ចាំងរបស់ព្រឹទ្ធសភាមានទម្ងន់ និងគ្រប់ជ្រុងជ្រោយដោយសារតែព្រឹទ្ធសភាជាតំណាងក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលជារដ្ឋបាលថ្នាក់ក្រោមបំផុត ព្រឹទ្ធសភាអាចធ្វើការតិះទៀន តាមរបៀបស្ថាបនាលើបញ្ហាជាតិ តាមរយៈដំណើរការសិក្សាស្រាវជ្រាវវាយ

[16] មាត្រា១៣៦-ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ និង
មាត្រា ១៦ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ឆ្នាំ១៩៩៨។

តម្លៃ និងកំណត់នូវចក្ខុវិស័យទៅមុខ ព្រមទាំងផ្ដល់នូវអនុសាសន៍ដែលរាជរដ្ឋាភិបាលងាយនឹងទទួលយក។

❖ **អំណាចសម្រេចចិត្ត**

រដ្ឋសភា និងព្រឹទ្ធសភាអាចប្រជុំរួមគ្នាជាសមាជ ដើម្បីដោះស្រាយបញ្ហាសំខាន់ៗរបស់ប្រទេសជាតិ[17]។

## សេចក្ដីសន្និដ្ឋាន

ទោះបីជាស្ថាប័នទាំងពីរ នេះមានសមត្ថកិច្ចអត្តសញ្ញា និងសមត្ថកិច្ចខុសគ្នាក៏ដោយ។ ប៉ុន្តែស្ថាប័នទាំងពីរនេះដែលជាអង្គការនីតិបញ្ញត្តិសំខាន់ដូចគ្នា ដែលមិនអាចខ្វះបាន ក្នុងការជួយត្រួតពិនិត្យច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដើម្បីឲ្យការអនុវត្តន៍ច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជាកាន់តែមានប្រសិទ្ធិភាព និងតម្លាភាព។

## ឯកសារពិគ្រោះ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ។
- ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ឆ្នាំ១៩៩៨ ។
- ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ១៩៩៧ និង ច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ ២០០៧ ។

**ចប់**

[17] មាត្រា ១១៦-ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។